# របាយការណ៍ស្ដីពី

# “ការបៀតបៀនទៅលើស្ត្រី និងក្មេងស្រី នៅព្រះរាជាណាចក្រកម្ពុជា”



ខែមីនា ឆ្នាំ២០២៣

# មាតិកា


និយមន័យ..........................................................................០១

សេចក្តីផ្តើម........................................................................០៤

I. ព័ត៌មានទូទៅ.....................................................................០៧

II. បទពិសោធន៍នៃការបៀតបៀន...............................................០៨

១. បទពិសោធន៍នៃការជួបការបៀតបៀន...........................០៨

២. ប្រភេទនៃការបៀតបៀន...............................................០៩

៣. ទីតាំងកើតហេតុ.........................................................១២

៤. សមាសភាពអ្នកប្រព្រឹត្តិ...............................................១៤

៥. ទំនាក់ទំនងរវាងអ្នកប្រព្រឹត្តិ និងជនរងគ្រោះ....................១៥

III. ការឆ្លើយតប បទពិសោធន៍នៃការរាយការណ៍ ការគាំទ្រ និងមតិត្រលប់ទៅកាន់ជនរងគ្រោះ............................................................១៥

១. ការឆ្លើយតបកំឡុងពេលកើតហេតុ..................................១៥

២. បទពិសោធន៍ នៃការរាយការណ៍...................................១៦

៣. ការគាំទ្រ និងមតិត្រលប់ទៅកាន់ជនរងគ្រោះ..................១៨

IV. ស្ថានភាពផ្លូវចិត្តរបស់ជនរងគ្រោះ.............................................២០

សេចក្តីសន្និដ្ឋាន....................................................................២០

អនុសាសន៍.........................................................................២៣

ឯកសារយោង......................................................................២៥

## និយមន័យ

- ការបៀតបៀន៖ គឺជាការប្រព្រឹត្តពីបុគ្គលណាម្នាក់ឬមួយក្រុម ដែលមិនត្រូវបានស្វាគមន៍ ដោយអ្នករងគ្រោះហើយគេយល់ថាបណ្តាលឱ្យមានការប្រមាថ ឬការបង្អាប់ដល់បុគ្គលដទៃ នៅពេលដែលការប្រព្រឹត្តបែបនេះរំខានដល់ការងារ ឬបង្កើតបរិយាកាសការងារដែលមានភាពបំភិតបំភ័យ ឬប្រមាថ។ ការបៀតបៀនអាចមានទម្រង់ដូចជា ពាក្យសម្តី កាយវិការ ឬសកម្មភាពដែលមានទំនោរទៅនឹងការរំខានការរំលោភបំពាន បំភិតបំភ័យ ប្រមាថ បន្ទាបខ្លួន ឬការធ្វើអោយអាម៉ាស់ផ្សេងទៀត( UN Women, 2020 )។

- ការបៀតបៀនផ្លូវភេទ៖ គឺជាការប្រព្រឹត្តណាមួយដោយបុគ្គលណាម្នាក់ ឬមួយក្រុមទៅលើបុគ្គលមួយ ឬច្រើនផ្សេងទៀតដែលមិនត្រូវបានស្វាគមន៍នៃធម្មជាតិផ្លូវភេទ ដែលនាំឱ្យប៉ះពាល់ដល់រាងកាយ ផ្លូវចិត្ត ឬផ្លូវភេទ ដែលអាចត្រូវបានគេយល់ឃើញថាបណ្តាលឱ្យមានភាពអាម៉ាស់នៅពេល ដែលការប្រព្រឹត្តបែបនេះរំខានដល់ការងារ គឺត្រូវបានបង្កើតជាលក្ខខណ្ឌការងារ ឬបង្កើតបរិយាកាសការងារដែលមាន ភាពបំភិតបំភ័យ ឬប្រមាថ មើលងាយ ( UN Women, 2020 ) ។

- ការបៀតបៀនតាមប្រព័ន្ធអនឡាញ៖ រាល់សកម្មភាពទាំងឡាយណាដែលស្តែងចេញ ឬអាចនាំឱ្យមាន ការប៉ះពាល់ឬការរងគ្រោះផ្នែករូបរាងកាយ ផ្លូវភេទ ឬផ្នែកសង្គម ដែលត្រូវបានប្រព្រឹត្តជម្រុញ ឬធ្វើឱ្យកាន់តែធ្ងន់ធ្ងរបន្ថែមទៀត ដោយមានការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនាក់ព័ត៌មាន ដូចជាប្រព័ន្ធផ្សព្វផ្សាយ សង្គម ទូរស័ព្ទចល័ត និងទូរស័ព្ទឆ្លាតវៃ ឬការប្រើប្រាស់អ៊ីនធើណែតបែបទូលំទូលាយផ្សេងទៀត ( លីកាដូ, ២០២១ )។

- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម៖ គឺជាកន្លែងមួយ (ហ្វេសប៊ុកតេឡេក្រាម តិកតុក យូធូប អ៊ីនស្តាក្រាមប៊ីហ្គោឡាយ) ដែលអនុញ្ញាត្តិឱ្យអ្នកប្រើប្រាស់ធ្វើការចែករំលែកព័ត៌មាន(រឿងរ៉ាវ) តាមអ៊ីនធើណែត ដើម្បីទំនាក់ទំនងទៅកាន់អ្នកដទៃផ្សេងទៀត តាមរយៈជាសារអក្សរ រូបភាព និងវីដេអូ។

- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានប្រពៃណី៖ គឺជាកន្លែងមួយ (ការសែត វិទ្យុ ទស្សនាវដ្ដី ទូរទស្សន៍)ដែលលោក អ្នកប្រើប្រាស់ទទួល និងចែករំលែកព័ត៌មាន តាមរយៈការអាន ការស្ដាប់ជាដើម ដើម្បីទំនាក់ទំនងទៅកាន់អ្នកដទៃផ្សេងទៀត។

## របកគំហើញសង្ខេប

ការស្ទង់មតិស្ដីពី **"ស្វែងយល់ពីស្ថានភាពការបៀតបៀនទៅលើស្ត្រី និងក្មេងស្រីនៅក្នុងព្រះរាជាណាចក្រកម្ពុជា"** ត្រូវបានធ្វើឡើងជាមួយស្ត្រី និងក្មេងស្រីចំនួន ៣៧០នាក់។ ការស្ទង់មតិនេះ ធ្វើឡើងតាមរយៈប្រព័ន្ធអនឡាញ និងការសម្ភាសន៍ដោយផ្ទាល់ចាប់ពីថ្ងៃទី២៤ ខែកុម្ភៈ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣។ ក្នុងចំណោមស្ត្រី និងក្មេងស្រីដែលចូលរួមក្នុងការស្ទង់មតិ ស្ត្រី និងក្មេងស្រីចំនួន២៤១នាក់ ធ្លាប់ទទួលរងការបៀតបៀន។ ហើយក្នុងចំណោមពួកគេដែលធ្លាប់រងការបៀតបៀន ស្ត្រី និងក្មេងស្រីចំនួន១៤៩នាក់ ធ្លាប់រងការបៀតបៀនលើសពីបីដង។ ការបៀតបៀនទាំងនោះស្តែងចេញតាមរយៈ ការប្រើប្រាស់ពាក្យសំដី ការបៀតបៀតលើរូបរាងកាយជាដើម។ ក្នុងចំណោមពួកគេ ស្ត្រី និងក្មេងស្រីចំនួនរហូតដល់ទៅ១០៩នាក់ ធ្លាប់រងការបៀតបៀនតាមប្រព័ន្ធអនឡាញ។ ជនប្រព្រឹត្តការបៀតបៀនមានទាំងភេទដូចគ្នា និងផ្ទុយគ្នា។ ជនប្រព្រឹត្តអំពើបៀតបៀនជាបុរសមានចំនួន២៣៩នាក់។ អំពើបៀតបៀនកើតឡើងដូចជានៅផ្សារឬកន្លែងលក់តវ៉ាន កន្លែងកំសាន្ត វាលស្រែ ឬចំការ សួនសាធារណៈ កន្លែងផ្តល់សេវាសង្គមសាធារណៈ និងកន្លែងផ្តល់សេវាឯកជន។

ក្នុងចំនោមស្ត្រី និងក្មេងស្រីដែលរងគ្រោះពីការបៀតបៀត មានតែស្ត្រី និងក្មេងស្រីត្រឹមតែ៣៥.១០ភាគរយប៉ុណ្ណោះ ដែល បានប្រាប់ ឬរាយការណ៍បញ្ហាដែលពួកគេជួបប្រទះ។ នៅពេលដែលស្ត្រី និងក្មេងស្រី៦៤.៩០ភាគរយផ្សេងទៀតឆ្លើយថា ខ្លួនមិនធ្លាប់បានប្រាប់ ឬរាយការណ៍ពីករណីនៃការទទួលរងអំពើបៀតបៀននោះទេ។ មូលហេតុដែលពួកគេសម្រេចចិត្តមិនរាយការណ៍ មានដូចជាការអៀនខ្មាស់ មិនមានទំនុកចិត្តចំពោះអ្នកដែលខ្លួនប្រាប់ ឬរាយការណ៍

ខ្លាចថាមិនមានអ្នកជឿ ខ្លាចទទួលរងការបន្ទោសបង្អាប់ និងខ្លាចរងនូវការគម្រាមកំហែងជាដើម។

ជនរងគ្រោះមួយចំនួនថា ខ្លួនធ្លាប់ទទួលបានយោបល់ត្រលប់នៅពេលដែលពួកគេប្រាប់ ឬរាយការណ៍អំពីករណីនៃការបៀតបៀននេះ ដូចជាការផ្តល់យោបល់ឱ្យផ្លាស់ប្តូរការប្រព្រឹត្តិ ទទួលបានសំណួរដាក់បន្ទុក ទទួលបានការជេរប្រមាទ ទទួលបានការទម្លាក់កំហុសជាដើម។ល។ បទពិសោធន៍ទាំងនោះបានធ្វើអោយស្ត្រី និងក្មេងស្រីទទួលរងនៅសម្ពាធមួយចំនួនរួមទាំងស្ថានភាពផ្លូវចិត្តជាអាទិ៍ ភាពភ័យខ្លាច អៀនខ្មាស ស្អប់ខ្ពើមខ្លួនឯង បាក់ស្បាត និងផ្តាច់ខ្លួនចេញពីក្រុមមនុស្ស ឬចេញពីសង្គមជាដើម។ របាយការណ៍នេះ ក៏បញ្ចូលអនុសាសន៍មួយចំនួនផងដែរ។

# សេចក្តីផ្តើម

ការបៀតបៀនស្ត្រី និងក្មេងស្រីបាននឹងកំពុងបន្តជាបញ្ហាប្រឈមដែលជាអំពើមួយរំលោភលើសិទ្ធិមនុស្សរបស់ស្ត្រី និងក្មេងស្រីយ៉ាងធ្ងន់ធ្ងរ។ស្ត្រី និងក្មេងស្រីបន្តទទួលរងគំនាប ការបន្ទោសបង្អាប់ ឬត្រូវបានចាត់ទុកថាមានស្លាកស្នាមមិនល្អនៅពេលដែលពួកគេទទួលរងអំពើបៀតបៀន។ ស្ត្រី និងក្មេងស្រីជាជនរងគ្រោះ ពីការបៀតបៀន មិនថាការបៀតបៀនដោយ ពាក្យសម្តី ការបៀតបៀនផ្លូវភេទ ឬក្នុងទម្រង់ផ្សេងៗទៀតនោះទេ ពួកគេហាក់ពុំសូវទទួលបានការលើកទឹកចិត្ត ការការពារ អន្តរាគមន៍ ឬទទួលបានយុត្តិធម៌ជាលក្ខណៈប្រព័ន្ធនៅឡើយទេ។ ទស្សនៈសាធារណជនដែលធ្វើការថ្កោលទោសអ្នកប្រព្រឹត្តិ ឬចាត់ទុកការបៀតបៀនជាអំពើខុសឆ្គងអំពើហិង្សាដែលរំលោភសិទ្ធិមនុស្ស ហាក់មានកម្រិតទាបនៅឡើយ។ ផងដែរនោះ ទស្សនៈរបស់សាធារណជន មួយចំនួនជាពិសេស អ្នកប្រើប្រាស់បណ្តាញព័ត៌មានសង្គមទៅលើអំពើបៀតបៀន ជារឿងធម្មតាដែលវាបន្ត កើតមាននៅក្នុងសង្គម។ ជារឿយៗ ស្ត្រីនិងក្មេងស្រីត្រូវបានកំណត់ ឬចាត់ទុកជាឧបករណ៍វាស់វែង វាយតម្លៃដោយវប្បធម៌ ប្រពៃណីនៅក្នុងសង្គម ដែលការចាត់ទុកនេះ បានបន្តដាក់សម្ពាធ និងកំណត់ដែននៃការប្រព្រឹត្តរបស់ស្ត្រីហើយវាក៏មិនបានជម្រុញឱ្យមានការបញ្ចប់អំពើហិង្សា ឬការបៀតបៀនគ្រប់រូបភាព និងគ្រប់ទម្រង់មកលើស្ត្រីនិងក្មេងស្រីនោះទេ។ បញ្ហាការបៀតបៀនដែលបានបន្តកើតឡើង មិនត្រូវបានចាត់ទុកជាបញ្ហាសម្រាប់បុគ្គលតែម្នាក់ ផ្ទុយទៅវិញវាជាបញ្ហាចម្បងដែលប្រទេសនីមួយៗ ត្រូវយកចិត្តទុកដាក់ជាចាំបាច់ និងត្រូវធ្វើការរួមគ្នា ដើម្បីបញ្ចប់បញ្ហានេះ។ របាយការណ៍សិក្សាស្រាវជ្រាវដោយអង្គការសិទ្ធិមនុស្សមួយចំនួនបង្ហាញឱ្យ ឃើញពីបញ្ហាធ្ងន់ធ្ងរនៃអំពើហិង្សា និងការបៀតបៀនដែលបន្តកើតឡើងនៅក្នុងប្រទេសកម្ពុជា។

ជាអាទិ៍របាយការណ៍សិក្សាស្រាវជ្រាវអង្គការលីកាដូ ដែលចេញផ្សាយនៅខែវិច្ឆិកា ឆ្នាំ២០២១ "ស្តីពីបច្ចុប្បន្នភាពការបៀតបៀនតាមប្រព័ន្ធផ្សព្វផ្សាយសង្គមកម្ពុជា" បានបង្ហាញថា ២០ភាគរយនៃស្ត្រីបាន វាយការណ៍ពីការបៀតបៀន

តាមប្រព័ន្ធអនឡាញ។ ការបៀតបៀនប្រព្រឹត្តក្នុងទម្រង់ផ្សេងៗមានដូចជាតាមរយៈអក្សរ ឬសាររូបភាព វីដេអូ ឬសំណើបែបផ្លូវភេទដែលពួកគេពុំបានស្នើសុំ។ ហើយតួលេខកើនដល់ ២៤ភាគរយសម្រាប់ស្ត្រីមានអាយុចន្លោះ ពី១៨ឆ្នាំ ដល់ ២៤ឆ្នាំ។ ស្របពេលជាមួយនេះគ្នាដែរ ៥៤ភាគរយនៃអ្នកឆ្លើយតប ទាំងអស់បានរាយការណ៍ថា បានឃើញមនុស្សត្រូវបានបៀតបៀនតាមប្រព័ន្ធអនឡាញ។ ក្នុងចំណោមនោះ ៨៦ភាគរយ បានឃើញស្ត្រីធ្លាប់ទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញស្របជាមួយគ្នា និងបុរស ២៦ភាគរយ ធ្លាប់ទទួលរងការបៀតបៀនតាមប្រព័ន្ធអនឡាញ (លីកាដូ, ២០២១) ។ របាយការណ៍នេះសបញ្ជាក់ឱ្យឃើញថា ស្ត្រី និងក្មេងស្រីបន្តទទួលរងការបៀតបៀនជាច្រើន និងត្រូវការការគាំទ្រ ការការពារ ការលើកទឹកចិត្ត និងដំណោះស្រាយយុត្តិធម៌សម្រាប់ពួកគេ។

## គោលបំណងនៃការស្ទង់មតិ និងវិធីសាស្ត្រ

ការស្ទង់មតិស្តីពី "ស្វែងយល់ពីស្ថានភាពការបៀតបៀនទៅលើស្ត្រី និងក្មេងស្រី នៅក្នុងព្រះរាជា ណាចក្រកម្ពុជា" ធ្វើឡើងក្នុងគោលបំណង ស្វែងយល់ពីបទពិសោធន៍ ស្ថានភាពប្រឈម និងផលប៉ះពាល់នានា ដែលស្តែងចេញពីការបៀតបៀនទៅលើស្ត្រី និងក្មេងស្រីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដើម្បីចងក្រង និងកសាងបទពិសោធន៍ និងភ័ស្តុតាងក្នុងការជម្រុញឱ្យបញ្ចប់ការបៀតបៀនគ្រប់ទម្រង់ និងគ្រប់រូបភាពមកលើស្ត្រី និងក្មេងស្រីនៅកម្ពុជា។ ការស្ទង់មតិនេះធ្វើឡើង ជាមួយស្ត្រី និងក្មេងស្រីមានអាយុ ចាប់ពីអាយុ១៦ឆ្នាំឡើងទៅ។ ការស្ទង់មតិនេះ ធ្វើឡើងជាមួយស្ត្រី និងក្មេងស្រីរស់នៅ ឬស្នាក់នៅបណ្តោះអាសន្នក្នុងតំបន់ទីក្រុងឬទីប្រជុំជន ព្រមទាំងតំបន់ជនបទមួយចំនួននៅកម្ពុជា។ ដំណើរការនៃការស្ទង់មតិនេះ ធ្វើឡើងដោយមានការចូលរួមស្ម័គ្រចិត្តពីស្ត្រី និងក្មេងស្រីតាមរយៈប្រព័ន្ធអនឡាញ និងតាមរយៈការផ្តល់បទសម្ភាសន៍ដែលធ្វើឡើងដោយក្រុមការងារស្ម័គ្រចិត្ត នៃអង្គការសកម្មសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ និង សមាគមមណ្ឌលព័ត៌មានកម្មករ។ ដោយយល់ឃើញថា ប្រជាពលរដ្ឋកម្ពុជាជាពិសេសស្ត្រី និងក្មេងស្រីដែលរស់ក្នុងតំបន់ ជនបទមួយចំនួនមិនមានលទ្ធភាពប្រើប្រាស់ ឬចូលរួមការស្ទង់មតិនេះតាមប្រព័ន្ធអនឡាញបាន ការប្រមូលពត៌មាននៃការស្ទង់មតិនេះធ្វើឡើងជាពីរទម្រង់ដូចបានរៀបរាប់ខាងលើ។

## I. ព័ត៌មានទូទៅ

អ្នកចូលរួមផ្តល់បទសម្ភាសន៍ មានចំនួន៣៧០នាក់។ ៤០.១ភាគរយនៃអ្នកចូលរួម ឬមានចំនួនស្មើនឹង១៣៧នាក់ មានអាយុចាប់ពី១៦ឆ្នាំដល់២០ឆ្នាំ ទន្ទឹមនឹងនេះ ២៣.១ភាគរយ នៃអ្នកឆ្លើយតប ឬស្មើ៧៩នាក់ មានអាយុចាប់ពី២១ឆ្នាំដល់២៥ឆ្នាំ។ ស្របពេលដែរ អ្នកចូលរួមស្ទង់មតិដែលមាន ១៤.៣ភាគរយ ឬ ៤៩នាក់ មានអាយុ៣៥ឆ្នាំឡើង។ ដោយឡែក អ្នកចូលរួមក្នុងការស្ទង់មតិមួយចំនួនទៀត ជ្រើសរើសមិនបង្ហាញអាយុរបស់ពួកគេឡើយ។



*តារាងអាយុនៃអ្នកផ្តល់បទសម្ភាសន៍*

អ្នកផ្តល់បទសម្ភាសន៍ភាគច្រើនមានមុខរបរជាសិស្ស/និស្សិត ដែលចំនួននេះមានរហូតដល់ទៅ៤៩ភាគរយ ស្មើនឹង១៦៩នាក់។ អ្នកចូលរួមក្នុងការស្ទង់មតិដែលធ្វើការជាបុគ្គលិក (អង្គការ ក្រុមហ៊ុនឯកជន ទីប្រឹក្សាឯករាជ្យ) មានចំនួន ១៧.៧ភាគរយ ឬ ៦១នាក់ ។ រីឯកម្មការិនី (កម្មការិនីធ្វើការក្នុងនិងក្រៅប្រព័ន្ធ) មានចំនួន ១៦.៥ ភាគរយ ឬចំនួន៨៧នាក់។ ស្រដៀងគ្នាទៅនឹងការឆ្លើយតបបង្ហាញពីអាយុរបស់អ្នកចូលរួមក្នុងការស្ទង់មតិស្ត្រី និងក្មេងស្រីមួយចំនួនជ្រើសរើសមិនឆ្លើយតបពីមុខរបរនិងការងាររបស់ពួកគេ។



*តារាងនៃ មុខរបរ និងការងារ*

អ្នកចូលរួមឆ្លើយតបអំពីទីលំនៅបច្ចុប្បន្នភាគច្រើន កំពុងរស់នៅ និងស្នាក់នៅក្នុងទីក្រុងភ្នំពេញ បណ្ដាខេត្តមួយចំនួនរួមមានខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ធំ។

## II. **បទពិសោធន៍នៃការបៀតបៀន**

### ១. **បទពិសោធន៍នៃការជួបការបៀតបៀនផ្លូវភេទ**

ក្នុងចំណោមអ្នកផ្ដល់បទសម្ភាសន៍ចំនួន៣៧០នាក់ ស្ត្រី និងក្មេងស្រីចំនួន ៦៤.៨ភាគរយ ឬស្មើនឹង២៤១នាក់ បានឆ្លើយថាពួកគេធ្លាប់ជួបការបៀតបៀន។




ក្នុងចំណោមអ្នកចូលរួមផ្ដល់បទសម្ភាសន៍បានរាយការណ៍ថា ពួកគេធ្លាប់ជួបការបៀតបៀន យ៉ាងតិចណាស់មួយដង។ ចំពោះស្ត្រី និងក្មេងស្រីដែលធ្លាប់ជួបបទពិសោធន៍មានចំនួន១៤ភាគរយ ឬស្មើរនឹង៣៣នាក់ ដែលធ្លាប់រងគ្រោះពីការបៀតបៀនចំនួនម្ដងមកទល់នឹងពេលផ្ដល់បទសម្ភាសន៍។ ហើយស្ត្រីនិងក្មេងស្រីមានចំនួន ៦៣.១ភាគរយ ឬស្មើរនឹង១៤៩នាក់ ធ្លាប់ទទួលរងការបៀតបៀនលើសពី៣ដងរហូតមកទល់នឹងពេលនៃការផ្ដល់បទសម្ភាសន៍។

# ចំនួនដងធ្លាប់ជួបការបៀតបៀន






*សរុប៖២៣៦នាក់ នៃអ្នកឆ្លើយតប*

## ២. ប្រភេទនៃការបៀតបៀន

### ការបៀតបៀនដោយប្រើប្រាស់ពាក្យសំដី

តាមរយៈការស្ទង់មតិ ដែលមានអ្នកចូលរួមចំនួន ៣៧០នាក់ ជនរងគ្រោះពីការបៀតបៀនមានចំនួន ២៤១នាក់។ ស្ត្រី និងក្មេងស្រីដែលរងគ្រោះ ដោយសារការប្រើប្រាស់ពាក្យសម្ដីមិនសមរម្យអំពី រូបរាងកាយ អាយុ ជីវិត ឯកជនមានភាគរយខ្ពស់បំផុត ក្នុងចំណោមប្រភេទនៃការបៀតបៀនទាំងអស់។ ចំពោះស្ត្រី និងក្មេងស្រីដែលធ្លាប់ទទួលរងការបៀតបៀនប្រភេទនេះ មានរហូតដល់ទៅ ៧៥.៤ភាគរយ ដែលស្មើនឹង ១៨១នាក់។ ចំនុចដែលគួរឱ្យកត់សម្គាល់បំផុតនោះ គឺសាធារណជនបានចាត់ទុក និងធ្វើឱ្យការបៀតបៀននេះមានលក្ខណៈធម្មតា និងមិនមែនជាបញ្ហាដែលគួរយកចិត្តទុកដាក់ឡើយ។ ការបៀតបៀនដោយចេតនាពីជនបង្កក្នុងទម្រង់ជាការពោល ពាក្យសសើរ ឬលួងលោមមានទំនោរទៅរកផ្លូវភេទ ទៅកាន់ជនរងគ្រោះមានចំនួន១៨.៣ភាគរយ។ ថ្វីត្បិតតែការបៀតបៀនប្រភេទនេះ មានភាគរយទាបបំផុត បញ្ហានេះនៅតែបង្កជាក្តីបារម្មណ៍សម្រាប់ សាធារណជន ពិសេសគឺជនបង្កប្រើមធ្យោបាយនេះ ជាផ្នាក់ក្នុងការសម្រេចគោលដៅរបស់ខ្លួន ប្រសិនបើ ជនរងគ្រោះមានភាពមិនពេញចិត្តលើរូបរាងកាយ ឬលក្ខណៈសម្បត្តិណាមួយរបស់ខ្លួន។





## ការបៀតបៀនរាងកាយ

មិនខុសគ្នាប៉ុន្មានពីការរងគ្រោះដោយពាក្យសម្តី ស្ត្រី និងក្មេងស្រីទទួលរងគ្រោះពីទម្រង់នេះ មានចំនួន ១០៩នាក់ ស្មើនឹង ៤៥.៤ភាគរយ។ ពួកគេទទួលរងការបៀតបៀនតាមរយៈការផ្តល់សញ្ញាកាយវិការ ដែលទាក់ទងទៅនឹងផ្លូវភេទដូចជា ការហួច ការសម្លក់សម្លឹងមកលើផ្នែកកេរ្តិ៍ភេទនៃរាងកាយរបស់ពួកគេជាដើម ។ល។ ទង្វើនេះ បង្កភាពមិនស្រណុកសុខស្រួល និងអារម្មណ៍អសុវត្ថិភាពទៅដល់ស្ត្រី និងក្មេងស្រីដែលជាអ្នកទទួលរងអំពើនេះ។



តាមរយៈលទ្ធផលពីការស្ទង់មតិនេះ ជនបង្កបានបញ្ចេញសកម្មភាព ក្នុងរូបភាពជាការជិះតាមឬដើរតាមស្ត្រី និងក្មេងស្រី ដែលជាជនរងគ្រោះ ហើយ សកម្មភាពនៃការបៀតបៀននេះមានចំនួន៣៣.៣ភាគរយ ដែលវាបានបង្កជា សម្ពាធទាំងផ្នែកផ្លូវកាយ និងផ្លូវចិត្តដោយនូវរាល់ឥរិយាបទ ឬការប្រព្រឹត្តរបស់ ពួកគាត់(ជនរងគ្រោះ) ត្រូវបានឃ្លាំមើលពីបុគ្គលដទៃទៀត។ បើទោះបីជា ជនរងគ្រោះ ដែលត្រូវបានរងគ្រោះដោយការស្នើដាក់លក្ខខណ្ឌដោះដូរដើម្បី បំពេញចំណង់ផ្លូវភេទផ្ទាល់ខ្លួនដូចជា ការផ្ទេរ ការដំឡើងឋានៈ ប្រាក់ខែ កិច្ចសន្យា ការងារ ឬប្រាក់រង្វាន់មានចំនួន ៦.៣ភាគរយ ធៀបនឹងចំនួនសរុបក្តី ប៉ុន្តែតួលេខ នេះនៅតែជាការព្រួយបារម្ភ មិនចំពោះតែការងារការសិក្សា ដៃគូ ឬមុខជំនួញ ឡើយ។ ជនបង្កនឹងប្រើមធ្យោបាយនេះដើម្បីឈ្លៀតឱកាសក្នុងការបំពេញចំណង់ របស់ខ្លួន ប្រសិនបើជនរងគ្រោះកំពុងស្ថិតនៅក្នុងតម្រូវការហិរញ្ញវត្ថុ ឬលក្ខខណ្ឌ ចាំបាច់ណាមួយ។



## ការបៀតបៀនតាមប្រព័ន្ធអនឡាញ

ជាទូទៅ ការបៀតបៀនផ្លូវភេទតាមប្រព័ន្ធបណ្តាញព័ត៌មានសង្គម ត្រូវ បានសាធារណៈជនមើលរំលង ទោះបីជាករណីនេះកំពុងតែ កើតមានឡើង នៅក្នុងសង្គមបច្ចុប្បន្នក៏ដោយ។ ការស្ទង់មតិបានបង្ហាញឱ្យឃើញថាការ បៀតបៀន ផ្លូវភេទ តាមប្រព័ន្ធបណ្តាញព័ត៌មានសង្គម តាមរយៈការផ្ញើរសារការ ចូលរួម យោបល់ ឬការខំមិន ការចែករំលែកផ្សេងៗ មានរហូតដល់ទៅ ១១៩នាក់

ស្មើនឹង ៤៧.៩ភាគរយ។ លើសពីនេះ ស្ត្រី និងក្មេងស្រីត្រូវបានមហាជនយកមកធ្វើជាឧបករណ៍នៅក្នុងការលេងសើច ការវាស់វែងតម្លៃ វប្បធ៌ម ប្រពៃណីសង្គម ការកំណត់ទៅលើតម្លៃស្ត្រីខ្មែរ និងភាពថ្លៃថ្នូររបស់បុគ្គលដែលជាស្ត្រី និងក្មេងស្រី ដោយការប្រើពាក្យពេជន៍ អសីលធ៌ម ជេរប្រមាថ ការសម្តែងទំនោរផ្លូវភេទ ការចោទប្រកាន់ ការដាក់បន្ទុក និងការបង្គាប់បញ្ជាឱ្យផ្លាស់ប្តូរការប្រព្រឹត្ត។ ម្យ៉ាងវិញទៀត ការបៀតបៀនប្រភេទនេះ ត្រូវបានធ្វើឡើងជាញឹកញាប់ពីសំណាក់ជនបង្ក មិនថាជាបុរស ឬស្ត្រីឡើយ រហូតក្លាយជាទម្លាប់ប្រចាំថ្ងៃ។




### ៣. ទីតាំងកើតហេតុ

ករណីនៃការបៀតបៀននេះ កើតមានឡើងនៅគ្រប់ទីកន្លែង ដោយមិនប្រកាន់ថាទីតាំងនោះជាទីសាធារណៈ ឬឯកជនឡើយ។ យោងតាមការស្ទង់មតិនេះ ស្ត្រី និងក្មេងស្រី ៦៥.៥ភាគរយ នៃ២៦៨នាក់ ត្រូវទទួលរងការបៀតបៀននៅតាមផ្លូវ ដែលយើងបានដឹងហើយថា ផ្លូវគឺជាទីសាធារណៈ ដែលគួរតែផ្តល់សុវត្ថិភាពទៅឱ្យជនគ្រប់រូប ប៉ុន្តែវាបែរជាផ្តល់ភាពអសន្តិសុខ និងក្តីបារម្ភទៅវិញ។ ផ្ទះស្នាក់ បន្ទប់ ឬផ្ទះជួល គួរតែជាទីដែលមានសុខដុមរមនា និងសុវត្ថិភាពសម្រាប់ជនគ្រប់រូប ផ្ទុយមកវិញ ទីលំនៅជាកន្លែងដែលមានជនរងគ្រោះពីការបៀតបៀន

រហូតដល់ទៅ ២៤.៨ភាគរយ។ ដូចគ្នានេះដែរ កន្លែងធ្វើការរួមបញ្ចូលទាំងស្ថាប័នរដ្ឋ និងឯកជន ជាទីតាំងដែលត្រូវបានរាយការណ៍ថា មានការបៀតបៀនស្មើទៅនឹងករណីដែលបានកើតឡើងនៅទីលំនៅផងដែរ។ ជាងនេះទៅទៀតការបៀតបៀននៅគ្រឹះស្ថានអប់រំនៅតែ បន្តកើតមានឡើងរហូតទៅដល់ ១៤.៣ភាគរយ។ បើទោះបីជា ទីតាំងនេះមានភាគរយនៃការបៀតបៀនទាបក៏ដោយ វានៅតែជាបញ្ហាដែលគួរតែយកចិត្តទុកដាក់ដោយសារតែគ្រឹះស្ថានអប់រំ មិនត្រឹមតែជាកន្លែងដែលផ្តល់ការ អប់រំដល់សិស្សានុសិស្ស និងបណ្តុះបណ្តាលធនធានមនុស្ស ដែលអាកប្បកិរិយានៃការបៀតបៀនមិនគួរកើតមានឡើងសូម្បីម្តង។




*ក្រាបនៃទីតាំងកើតហេតុ*

ការបៀតបៀននេះក៏កើតមានឡើងនៅទីតាំងមួយចំនួនដូចជា៖

- ផ្សារ/កន្លែងលក់អីវ៉ាន់មានចំនួន ១៤.៣ភាគរយ
  កន្លែងកំសាន្ត(ក្លឹប ខារ៉ាអូខេ រង្គសាល) មានចំនួន ១២.៦ភាគរយ
- វាលស្រែ/ចំការ មានចំនួន ៥.៩ភាគរយ
- សួនសាធារណៈ មានចំនួន ២៣.១ភាគរយ
- កន្លែងផ្តល់សេវាសង្គមសាធារណៈ (មន្ទីរពេទ្យ សាលារៀន/មហាវិទ្យាល័យមធ្យោបាយធ្វើដំណើរផ្សេងៗ)មានចំនួន២២.៧ភាគរយ
- កន្លែងផ្តល់សេវាឯកជន (មន្ទីរពេទ្យ សាលារៀន/មហាវិទ្យាល័យ មធ្យោបាយធ្វើដំណើរ ផ្សេងៗ) មានចំនួន៨.៤ភាគរយ

ការស្ទង់មតិនេះ បានសបញ្ជាក់ផងដែរថា គ្មានកន្លែងណាមួយដែលជាទីសុវត្ថិភាពសម្រាប់ស្ត្រីឡើយ ទោះបីជាយើងកំពុងតែស្ថិតនៅក្នុងសតវត្សរ៍ទី២១នេះក៏ដោយ។

## ៤. សមាសភាពអ្នកប្រព្រឹត្ត

ក្នុងចំណោមស្ត្រីនិងក្មេងស្រីជាជនរងគ្រោះចំនួន ២៣៩នាក់ ស្មើនឹង ៨៦.៩ភាគរយ បានបញ្ជាក់ថា ពួកគាត់ទទួល បានបទពិសោធន៍នៃការបៀតបៀនពីជនបង្កឬអ្នកប្រព្រឹត្តជាបុរស។ ជនរងគ្រោះប្រមាណ ៤៧.៩ភាគរយ ទទួលបានការប្រើប្រាស់ពាក្យសម្តីមិនសមរម្យអំពីរូបរាងកាយ ពីសំណាក់ជនបង្កដែលមានភេទដូចគ្នា។ ម៉្យាងទៀត ស្ត្រីនិងក្មេងស្រី ១០.៦ភាគរយ ទទួលបានបទពិសោធន៍នៃការបៀតបៀនពីភេទផ្សេងៗ។



**៨៦.៩ភាគរយ រងគ្រោះពីបុរស**



**៤៧.៩ភាគរយ រងគ្រោះពីស្ត្រី**



**១០.៦ភាគរយ រងគ្រោះពីភេទផ្សេងៗ**

ស្ត្រី និងក្មេងស្រីជាជនរងគ្រោះចំនួន ៨៣.៧ភាគរយ បានបញ្ជាក់ថា ពួកគាត់រងគ្រោះពីជនបង្កជាបុគ្គល។ ៥០.៦ភាគរយ បានបញ្ជាក់ថា ជនបង្ក/អ្នកប្រព្រឹត្ត បានបង្កើតរូបភាពនៃការបៀតបៀនជាក្រុម។ ថ្វីត្បិតតែ ភាគរយនៃជនបង្កជាក្រុមទាបជាងជនបង្កជាបុគ្គល តែវានៅតែជាចំណុចដែលគួរឱ្យយកចិត្តទុកដាក់បំផុត ដោយសារតែក្រុមមានសមាជិកច្រើន អាចបង្កជាការភ័យខ្លាច និងហានិភ័យខ្ពស់។

*ក្រាបនៃជន បង្កហេតុ*



## ៥. ទំនាក់ទំនងរវាងអ្នកប្រព្រឹត្ត និងជនរងគ្រោះ

អ្នកចូលរួមស្ទង់មតិចំនួន ២៣៨នាក់ ស្មើនឹង៦៥.៥ភាគរយ បានបង្ហាញថាពួកគាត់រងគ្រោះពីជនមិនស្គាល់គ្នា ។ ជនរងគ្រោះបានបន្តថា ពួកគាត់ទទួលរងការបៀតបៀនពីមិត្តភក្តិឬអ្នកស្គាល់គ្នាប្រមាណ ៦៤.៧ភាគរយ នៃអ្នកចូលរួមស្ទង់មតិសរុប។ ២០.៦ភាគរយនៃជនរងគ្រោះ បានរាយការណ៍ថាពួកគាត់ក៏ទទួលរងទង្វើនេះពី សំណាក់សាច់ញាតិខ្លួនផងដែរ។




## III. ការឆ្លើយតប បទពិសោធន៍នៃការរាយការណ៍ ការគាំទ្រ និងមតិត្រលប់ទៅកាន់ជនរងគ្រោះ

### ១.ការឆ្លើយតបកំឡុងពេលកើតហេតុ

ក្នុងកំឡុងពេលដែលអ្នកជួបបទពិសោធន៍នៃការបៀតបៀន ពួកគាត់បានបង្ហាញប្រាប់អំពីប្រតិកម្មរហ័ស នៅពេលពួកគាត់ស្ថិតក្នុងស្ថានភាពនៃពេលកើតហេតុការណ៍ដូចជា៖



នៅស្ងៀមស្ងាត់ មិនហ៊ានតបតមានចំនួន ៥៤.៤ ភាគរយ



មិនដឹងថាត្រូវតបតយ៉ាងដូចម្តេច ឬឆ្លើយបែបណាទៅអ្នកប្រព្រឹត្តិ មានចំនួន ៣៥.៦ភាគរយ



ឆ្លើយតបតដោយអហិង្សា ដោយការពន្យល់ ព្យាយាមបង្វែរស្ថានការណ៍មានចំនួន ២២.៦ភាគរយ



ហិង្សាវិញភ្លាមៗតាមរយៈ ជេរប្រទិច វាយតប់ សម្លក់សម្លឹងមានចំនួន ៣០.១ ភាគរយ



ប្តូកគណនេយ្យជនបង្កហេតុ មានចំនួន ៤៣.៥ភាគរយ

## ២.បទពិសោធន៍ នៃការរាយការណ៍

ក្នុងចំណោម ២៤២នាក់ នៃអ្នកផ្តល់ចំលើយក្នុងការស្ទង់មតិអំពីបទពិសោធន៍នៃការរាយការណ៍ និងចែករំលែកអំពីករណីនៃការបៀតបៀនផ្លូវភេទដែលខ្លួនបានជួបប្រទះរហូតដល់ទៅ ៦៤.៩០ភាគរយ មិនធ្លាប់បានប្រាប់ឬរាយការណ៍ពីករណីនៃការបៀតបៀន របស់ខ្លួន ទៅឪពុកម្តាយ សាច់ញាតិ អាជ្ញាធរមូលដ្ឋាន អង្គការ សង្គមស៊ីវិល និងក្រុមការងារមិត្តភ័ក្រ្តនោះទេ ។ ទន្ទឹមនឹង ៣៥.១០ ភាគរយទៀតឆ្លើយថា គាត់ធ្លាប់បានប្រាប់ និងរាយការណ៍ពីករណីនៃការបៀតបៀន និងការបៀតបៀនផ្លូវភេទចំពោះគាត់។ ក្នុងនោះអ្នកធ្លាប់ជួបប្រទះពិសោធន៍ ធ្លាប់បានរាយការណ៍ឬប្រាប់ច្រើនជាងគេទៅកាន់ ក្រុមការងារមិត្តភ័ក្តដែលមានចំនួន ៧៥ភាគរយ ប្រាប់ទៅ ឪពុកម្តាយមានចំនួន ៦០ភាគរយ បានប្រាប់ទៅសាច់ញាតិមានចំនួន ៤៣ភាគរយ។ ជនរងគ្រោះបានចែករំលែកពីករណីនៃការបៀតបៀននេះនៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម មានចំនួន ១៣ភាគរយ ។




*ក្រាបនៃមូលហេតុនៃការមិនរាយការណ៍*

ផងដែរនោះ ចំណុចដែលគួរឱ្យចាប់អារម្មណ៍ចំពោះអ្នកដែលទទួលបទពិសោធន៍នៃការបៀតបៀន បង្ហាញថាខ្លួន មិនបានប្រាប់ ឬរាយការណ៍ទៅកាន់បុគ្គលទីបីដោយសារតែមូលហេតុ៖

- អៀនខ្មាស
- មិនមានទំនុកចិត្តចំពោះអ្នកដែលខ្លួនប្រាប់ឬរាយការណ៍ដើម្បីសុំជំនួយ
- បារម្ភថាមិនមានអ្នកណាជឿ
- បារម្ភថាត្រូវបានគេសន្មត់ខ្លួនក្នុងន័យអវិជ្ជមាន
- ទទួលបាននូវពាក្យបន្ទោសបង្អាប់
- ខ្លាចរងនូវការចោទប្រកាន់ថាខ្លួនទាមទារចំណាប់អារម្មណ៍
- ស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះចំនួនមាន៧នាក់ បានប្រាប់ថាខ្លួនមិនហ៊ានរាយការណ៍ ពីព្រោះខ្លាចរងនូវការគម្រាមកំហែងដូចជាបញ្ឈប់ការងារ ធ្វើឃាត បកអាក្រាត និងការបំបិទពីការទទួលបានផលប្រយោជន៍ផ្សេងៗទៀត ។

នេះសបញ្ជាក់ឱ្យឃើញថានៅក្នុងសតវត្សរ៍ទី២១ នេះទៅហើយ អ្នកដែលធ្លាប់ទទួលបានបទពិសោធន៍នៃការបៀតបៀនភាគច្រើន មិនហ៊ានរាយការណ៍ទៅ អាជ្ញាធមូលដ្ឋាន ឬប្រាប់ទៅ ឪពុកម្ដាយ សាច់ញាតិ មិត្តភ័ក្ត ឬក្រុមការងារនោះទេ គឺដោយសារតែពួកគាត់ខ្លាចត្រូវទទួលរងនូវការស្ដីបន្ទោសបង្អាប់ ទៅលើរូបរាងកាយ ការប្រព្រឹត្ត ការស្លៀកពាក់ ការវិនិច្ឆ័យសន្មត់ក្នុងន័យអវិជ្ជមាន

ការចោទប្រកាន់ថា ខ្លួនជាអ្នកទាមទារចំណាប់ អារម្មណ៍ដែលធ្វើឱ្យគេបៀតបៀនខ្លួន ឬខ្លួនជាមូលហេតុ ដែលនាំឱ្យមានការបៀតបៀនទៅវិញ បើទោះបីខ្លួនជាជនរងគ្រោះក៏ដោយ ។ ផ្នត់គំនិត ប្រពៃណី វប្បធម៌អវិជ្ជមានមួយចំនួន ជាពិសេសការស្តីបន្ទោស ការដាក់គំនាបទៅលើជនរងគ្រោះ អំពីការបៀតបៀននៅតែជាបញ្ហាប្រឈម ឧបសគ្គសម្រាប់ស្ត្រីក្នុងការបង្ហាញប្រាប់ ការស្វែងរកការពារគាំទ្រ និងស្វែងរកយុត្តិធម៌សម្រាប់ខ្លួន។

## ៣.ការគាំទ្រ និងមតិត្រលប់ទៅកាន់ជនរងគ្រោះ

ក្នុងចំនោម ៦៦នាក់ នៃចំនួន៨៤នាក់នៃស្ត្រី និងក្មេងស្រីរងគ្រោះ ដែលស្វែងរកការគាំទ្រពីគ្រួសារបានបង្ហាញថា ពួកគេទទួលបានការគាំទ្រ ពីគ្រួសារបន្ទាប់ពីការប្រាប់ ឬចែករំលែកករណីនៃការបៀតបៀនដែលកើតឡើង លើពួកគេ។ ដោយឡែក ស្ត្រី និងក្មេងស្រីដែលរងគ្រោះចំនួន ១៨នាក់ផ្សេងទៀតមិនទទួលបានការគាំទ្របែបនេះពីគ្រួសាររបស់ពួកគាត់នោះទេ។ ស្របពេលដែល ស្ត្រីនិងក្មេងស្រីចំនួន ៧៧នាក់ ក្នុងចំណោម៩១នាក់នៃអ្នកឆ្លើយតប ថាពួកគេទទួលបានការគាំទ្រ និងលើកទឹកចិត្តពីមិត្តភ័ក្តិរបស់ពួកគាត់។ ដោយឡែកមានតែ១៧នាក់ ប៉ុណ្ណោះក្នុងចំណោម ៧៣នាក់ នៃអ្នកឆ្លើយតបថា បានទទួលការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ឬស្ថានប័នពាក់ព័ន្ធ។

បន្ទាប់ពីការបង្ហាញ ការប្រាប់ការចែករំលែក និងរាយការណ៍ពីករណីនៃការបៀតបៀន អ្នកចូលរួមក្នុងការស្ទង់ មតិនេះ ទទួលបានយោបល់ត្រលប់ទាំងវិជ្ជមាន និងអវិជ្ជមានដូចជា៖

- ទទួលបានការលើកទឹកចិត្ត
- ទទួលបានការផ្តល់យោបល់ឱ្យពួកគាត់ផ្លាស់ប្តូរ អាកប្បកិរិយា ឬការប្រព្រឹត្ត ដូចជា៖ការស្លៀកពាក់ ការដេក ដើរ ឈរ អង្គុយ
- ទទួលបានការទម្លាក់កំហុសទាក់ទងនឹងបញ្ហាដែលពួកគេទទួលរងគ្រោះ
- ទទួលបានសំណួរដាក់បន្ទុកបន្ថែម

- ទទួលបានការសន្ទត់ឬវាយតម្លៃក្នុងន័យអវិជ្ជមាន
- ទទួលបានការជេរប្រមាថ




ការស្ទង់មតិនេះបានបង្ហាញថា ជិតពាក់កណ្តាលនៃការចែករំលែកអំពីករណីនេះ ត្រូវបានផ្តល់យោបល់ត្រលប់ឱ្យជនរងគ្រោះផ្លាស់ប្តូរអាកប្បកិរិយា ឬការប្រព្រឹត្តដូចជា ការស្លៀកពាក់ ការដេក ដើរ ឈរ អង្គុយជាដើម។ល។ ការណ៍នេះហាក់បង្ហាញថា ជនរងគ្រោះត្រូវបានប្រាប់ឱ្យការពារខ្លួន ក្រោមរូបភាពនៃការបារម្ភអំពីសុខសុវត្ថិភាព ប៉ុន្តែប្រសិនបើយើងគិតឱ្យស៊ីជម្រៅតើវាពិតជាត្រឹមត្រូវទេ នៅពេលដែលអ្នកជាជនរងគ្រោះហើយត្រូវបានប្រាប់ឱ្យការពារ ឬផ្លាស់ប្តូរខ្លួនឯង ជាងចាត់ចំណាត់ការក្នុងការដាក់ទោសជនប្រព្រឹត្តិ។ វាហាក់បង្ហាញថា សិទ្ធសេរីភាព ការសម្រេចចិត្ត ការបង្ហាញ ការស្លៀកពាក់ ការប្រព្រឹត្តខ្លួនរបស់ស្ត្រីត្រូវបានរិតត្បិត ដាក់សម្ពាធ ដោយប្រយោលក្នុងរូបភាពនៃការការពារទៅវិញ។ ជារឿយៗ ការប្រព្រឹត្តរបសជនល្មើស ហាក់មិនត្រូវបានចោទជាសំណួរ។

## IV. ស្ថានភាពផ្លូវចិត្តរបស់ជនរងគ្រោះ

តាមលទ្ធផលដែលទទួលបាន ស្រ្តី និងក្មេងស្រីជនរងគ្រោះចំនួន ២៨.៩ភាគរយប៉ុណ្ណោះ ដែលមានស្ថានភាព ផ្លូវចិត្តនឹងន។ បន្ទាប់ពីហេតុការណ៍ នេះកើតឡើង ជនរងគ្រោះចំនួន ៥១ភាគរយ មានស្ថានភាពផ្លូវចិត្តភ័យខ្លាច។ ចំណែកឯស្ត្រី និងក្មេងស្រីជាជនរងគ្រោះចំនួន ៣៩.៧ភាគរយ ផ្សេងទៀតមាន អារម្មណ៍អៀនខ្មាសខុសពីធម្មតា។ ចំណុចដែលមានភាពលេចធ្លោជាងគេគឺ ស្ត្រី និងក្មេងស្រីជាជនរងគ្រោះ ចំនួន១៧.២ភាគរយ មានភាពបាក់ស្បាតដែលធ្វើ ឱ្យពួកគាត់មានប្រតិកម្មមួយចំនួន រាល់ពេលដែលពួកគាត់ចងចាំ ឬឃើញទីតាំង កើតហេតុណាមួយ។




## សេចក្តីសន្និដ្ឋាន

ស្ត្រី និងក្មេងស្រីបន្តទទួលរងការបៀតបៀនជាច្រើនទម្រង់ និងគ្រប់រូប ភាព ដែលអំពើនេះវាបានរំលោភទៅលើសិទ្ធិមនុស្សរបស់ស្ត្រីយ៉ាងធ្ងន់ធ្ងរ។ ជា អាទិ៍ចំនួននៃអ្នកឆ្លើយតបថាធ្លាប់ទទួលរងគ្រោះពីអំពើបៀតបៀន មានដល់រហូត ទៅ ៦៤.៨ភាគរយ ឬស្មើទៅនឹងចំនួនស្ត្រីនិងក្មេងស្រី ២៤១នាក់ ក្នុងចំណោម ស្ត្រីនិងក្មេងស្រីដែលចូលរួមក្នុងការស្ទង់មតិសរុបចំនួន ៣៧០នាក់។ ជាមួយគ្នា នេះដែរ បើពិនិត្យលើចំនួនដង ដែលស្ត្រីនិងក្មេងស្រីធ្លាប់ទទួលរងគ្រោះ

ពីការបៀតបៀនវិញ ស្ត្រីនិងក្មេងស្រី៣៣នាក់ បានរាយការណ៍ថាយ៉ាងហោចណាស់ពួកគេធ្លាប់ជួបបញ្ហានេះ១ដង។ ស្ត្រីនិងក្មេងស្រីចំនួន ១៤៩នាក់ផ្សេងទៀត ធ្លាប់ទទួលរងអំពើហិង្សាពីការបៀតបៀននេះចាប់ពី៣ដងឡើងទៅ។ បញ្ហានេះសបញ្ជាក់ឱ្យឃើញថា អំពើបៀតបៀនមកលើស្ត្រីនិងក្មេងស្រី មិនត្រូវបានចាត់ទុកជាបញ្ហាការរំលោភបំពានអំពើហិង្សា ឬការរំលោភសិទ្ធិមនុស្សស្ត្រីដែលត្រូវតែដោះស្រាយ ឬបញ្ចប់ជាដាច់ខាតនោះទេ។ ប៉ុន្តែស្ត្រីនិងក្មេងនៅតែបន្តប្រឈមទៅនឹងអំពើហិង្សា និងការបៀតបៀននេះនៅស្ទើគ្រប់ទីកន្លែង មិនថាជាកន្លែងសាធារណៈ នៅកន្លែងស្នាក់នៅ កន្លែងធ្វើការជាដើម។ល។ ទន្ទឹមនឹងនេះ ស្ត្រី និងក្មេងស្រីដែលចូលរួមក្នុងការស្ទង់មតិនេះ បានរាយការណ៍ថា អ្នកប្រព្រឹត្តអំពើបៀតបៀនភាគច្រើនជាបុរស ដែលមានចំនួនរហូតដល់ទៅ៨៦.៩ភាគរយ បើធៀបទៅនិងស្ត្រីដែលមានចំនួន៤៧.៩ភាគរយ។ យ៉ាងណាមិញ បន្ទាប់ពីធ្លាប់ជួបការបៀតបៀនស្ត្រី និងក្មេងស្រីជាជនរងគ្រោះភាគច្រើន ជ្រើសរើសមិនប្រាប់ឬរាយការណ៍ទៅអាជ្ញាធរ ឬស្វែងរកការគាំទ្រនោះទេ។ ក្នុងចំណោមស្ត្រីនិងក្មេងស្រីដែលជ្រើសរើសមិនរាយការណ៍មានចំនួន ១៤២នាក់ នៃអ្នកឆ្លើយតបសរុប។ ផងដែរនោះ មូលហេតុដែលស្ត្រី និងក្មេងស្រីជាជនរងគ្រោះភាគច្រើនមិនបានរាយការណ៍ ឬប្រាប់ទៅឪពុកម្តាយ អាណាព្យាបាល មិត្តភក្តិនៅពេលមានការបៀតបៀនកើតឡើងមកលើពួកគេដោយសារកត្តា និងមូលហេតុមួយចំនួនក្នុងនោះរួមមាន៖ ពួកគាត់មានភាពខ្មាស់អៀន ដោយភាគរយនៃស្ត្រី និងក្មេងស្រីជាជនរងគ្រោះមានរហូតដល់ទៅ ៥៧.៣ភាគរយ ចំណែកឯ ៤៨.៤ភាគរយផ្សេងទៀត បានឆ្លើយថាមិនមានទំនុកចិត្តក្នុងការរាយការណ៍ដើម្បី សុំកិច្ចអន្តរាគមន៍។ ស្ត្រីនិងក្មេងស្រីមួយចំនួនមិនរាយការណ៍ដោយសារមានក្តីបារម្ភថា មិនមានអ្នកជឿចំពោះបទពិសោធន៍ការទទួលរងការបៀតបៀនរបស់ពួកគេ ដែលភាគរយនៃស្ត្រីនិងក្មេងស្រីមានក្តីបារម្ភនេះ មានចំនួន ២៩.៩ភាគរយ។ អ្វីដែលសំខាន់ជាងនេះ បន្ទាប់ពីជួបការបៀតបៀន ពួកគាត់ភាគច្រើនត្រូវបានអ្នកជុំវិញខ្លួនផ្តល់យោបល់ដោយឱ្យផ្លាស់ប្តូរអាកប្បកិរិយា ឬ

ការប្រព្រឹត្តដូចជាការស្លៀកពាក់ ការដេក ដើរ ឈរ អង្គុយជាដើម។

ជាមួយគ្នានេះដែរ ក្រុមការងារក៏បានធ្វើការអង្កេតការបៀតបៀននៅ លើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមហ្វេកប៊ុកក្នុងអំឡុងរយៈពេល៣ខែ ចាប់ពីខែមករាដល់ខែមីនា ឆ្នាំ២០២៣ ហើយអ្វីដែលរកបានឃើញ ភាគច្រើនស្ត្រីនិងក្មេងស្រីជាជនរកគ្រោះជាងបុរស។ ចំពោះជនបង្កមានទាំងស្ត្រីនិងបុរស។ ស្ត្រីដែលធ្វើការបៀតបៀនតាមរយៈ ការប្រើប្រាស់ពាក្យសម្តីមិនសមរម្យទៅលើរូបរាងកាយអាយុ អាកប្បកិរិយាឬការប្រព្រឹត្ត ការស្លៀកពាក់ ការនិយាយស្តី ការជ្រើសរើសមុខរបរ និងការសម្រេចចិត្តផ្សេងៗ របស់ស្ត្រីនិងក្មេងស្រីដទៃផ្សេងទៀតក្រោមហេតុផលនានា។ រីឯជនបង្កជាបុរសបានធ្វើអំពើបៀតបៀន តាមរយៈការ ប្រើប្រាស់ពាក្យសម្តីមិនសមរម្យសំដៅរកផ្លូវភេទ តាមរយៈសកម្មភាពដូចជា ការបញ្ចេញមតិយោបល់ ការចែកចាយរូបថត ឬវីដេអូបន្តដោយគ្មានការអនុញ្ញាតពីម្ចាស់គណនេយ្យហ្វេកប៊ុកផ្ទាល់ខ្លួន និងឆាតដោយការផ្ញើសារជាអក្សរសំណើបែបផ្លូវភេទ ដូច្នេះស្ត្រីនិងក្មេងស្រីត្រូវបានរឹតត្បឹតសិទ្ធិសេរីភាពក្នុងការរស់នៅប្រចាំថ្ងៃក៏ដូចជាការរើសអើង ការបៀតបៀននិងបៀតបៀនផ្លូវភេទគ្រប់ទម្រង់។ ចំណុចដែលខុសគ្នារវាងអំពើបៀតបៀនដែលបង្កដោយស្ត្រី និងបុរសនៅត្រង់ចំណុចដែលអំពើដែលបៀតបៀនចេញពីបុរសគឺមានលក្ខណៈសំដៅដល់ភេទ ការស្នើរួមភេទ ការបង្ហាញកេរ្តិ៍ ភេទឬអាវៈយវៈភេទរបស់ខ្លួនជាដើមទៅកាន់ស្ត្រីនិងក្មេងស្រី។ ការបៀតបៀនទាំងនេះមិនត្រូវបានចាត់ទុកជាបញ្ហាការរំលោភសិទ្ធិនិងអំពើហិង្សាធ្ងន់ធ្ងរមកលើស្ត្រីនិងក្មេងស្រីនោះទេ។ វាហាក់ត្រូវបានចាត់ទុកជាបញ្ហាធម្មតា ហើយជារឿយៗ ស្ត្រីនិងក្មេងស្រីទទួលរងគ្រោះម្តងទៀតពិសេសចំពោះការយល់ឃើញ ឬទស្សនមហាជនទៅលើមូលហេតុនៃការប្រព្រឹត្តអំពើខុសច្បាប់ និងភាពមិនត្រឹមត្រូវនេះ។

ដូចនៅបណ្តាប្រទេសជាច្រើនក្នុងពិភពលោក ប្រទេសកម្ពុជា ស្ត្រីនិងក្មេងស្រីក៏ទទួលរងការបៀតបៀនជាច្រើនទម្រង់ បើទោះបីសព្វថ្ងៃស្ថិតក្នុងសតវត្សរ៍ទី២១ក្តី ស្ត្រីនិងក្មេងស្រី ភាគច្រើនជាជនរងគ្រោះបាននឹងកំពុងដាក់

គំនាប ស្តីបន្ទោស និងយកជាឧបករណ៍សម្រាប់វាស់វែងពីតម្លៃសង្គម វប្បធម៌ប្រពៃណី។ ខណៈដែរប្រទេសកម្ពុជាបានចូលជាសមាជិក នៃកតិកាសញ្ញានានាក្នុងឆ្នាំ ១៩៩២ ដែលក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងទទួលស្គាល់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ជាផ្នែកមួយនៃច្បាប់កម្ពុជា ក្នុងនោះមាត្រា២បានចែងថា *"មនុស្សម្នាក់ៗ អាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយមានជាអាទិ៍ពូជសាសន៍ ពណ៌សម្បុរភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិឬសង្គម ទ្រព្យសម្បិត្តិ កំណើត ឬស្ថានភាពដទៃទៀតឡើយ"* និងមាត្រា២៣បានចែងថា *"មនុស្សគ្រប់រូប មានសិទ្ធិមានការងារធ្វើ ជ្រើសរើសការងារដោយសេរី ទទួលលក្ខខណ្ឌការងារត្រឹមត្រូវនិងពេញចិត្ត"* *(ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិប្រចាំកម្ពុជា, ២០០៤)។ ហេតុដូច្នេះ ការបៀតបៀននិងការបៀតបៀនផ្លូវភេទគឺ ប្រឆាំងទៅនឹងសិទ្ធមនុស្សជាសាកល ច្បាប់ការងារនិងក្រមព្រហ្មទណ្ឌនៃប្រទេសកម្ពុជា មាត្រា ២៣៩ និងមាត្រា ២៤៦ ។*

**អនុសាសន៍៖**

សាធារណជន

- បញ្ឈប់ការប្រើប្រាស់អំពើហិង្សា ការបៀតបៀន និងការរើសអើងគ្រប់ទម្រង់មកលើស្ត្រី
- បញ្ឈប់វប្បធម៌ដាក់បន្ទុក និងស្តីបន្ទោសមកលើស្ត្រីជាជនរងគ្រោះ
- បញ្ឈប់វប្បធម៌នៃការប្រើប្រាស់អំណាច និងបុព្វសិទ្ធិរបស់ខ្លួនមកលើស្ត្រី និងក្មេងស្រី
- គោរពសិទ្ធិ និងជម្រើសស្ត្រីទៅលើការសម្រេចចិត្ត ជម្រើសក្នុងការស្លៀកពាក់ ជម្រើសចំណង់និងការកំណត់អត្តសញ្ញាណភេទ ជម្រើសការងារនិងមុខរបប និងការប្រព្រឹត្តខ្លួនជាដើម

- បញ្ចប់ការយកស្ត្រីជាឧបករណ៍នៅក្នុងការវាស់វែងតម្លៃសង្គម វប្បធម៌ ប្រពៃណី ពិសេសវប្បធម៌និងប្រពៃណីដែលដាក់គំនាបមកលើស្ត្រី និងក្មេងស្ត្រី។

រដ្ឋាភិបាល

- ស្នើដល់រាជរដ្ឋាភិបាលបង្កើតឱ្យមានលំហសុវត្ថិភាពសម្រាប់ស្ត្រី នៅក្នុងការចែករំលែកអំពីបញ្ហា
- ស្នើក្រសួងកិច្ចការនារី ជម្រុញការតាមដាន និងត្រួតពិនិត្យទៅលើកិច្ចអន្តរាគមន៍យន្តការដោះស្រាយរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារនៅតាមឃុំសង្កាត់ និងថ្នាក់ជាតិដោយធ្វើឱ្យប្រាកដថាស្ត្រីរងគ្រោះទទួលបានដំណោះស្រាយយុត្តិធម៌ ទទួលបានការការពារ និងការគាំទ្រនានាដែលចាំបាច់
- ស្នើដល់រាជរដ្ឋាភិបាលបង្កើនការអប់រំ និងចំណេះដឹងពីការបៀតបៀនទៅលើស្ត្រី និងក្មេងស្រីទៅដល់សាធារណជនទូទៅ ព្រមទាំងសង្គមគ្រួសារឱ្យបានទូលំទូលាយ
- ស្នើដល់រាជរដ្ឋាភិបាលជម្រុញឱ្យអនុវត្តច្បាប់ចំពោះជនប្រព្រឹត្តអំពើហិង្សា និងការបៀតបៀន
- ស្នើឱ្យមានកិច្ចពិគ្រោះយោបល់ទូលំទូលាយនៅពេលមានការធ្វើសេចក្តីព្រាងច្បាប់នានាពាក់ព័ន្ធនិងការបញ្ចប់ហិង្សាមកលើស្ត្រី និងក្មេងស្រី។

# ឯកសារយោង


- ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (១៩៤៨). សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស. កម្ពុជា. យកមកវិញពី មីនា ១៨, ២០២៣, ទៅ https://www.ohchr.org/
- សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (២០២១). បច្ចុប្បន្នភាពស្ថានភាព៖ ការបៀតបៀនតាមប្រព័ន្ធផ្សព្វផ្សាយសង្គមកម្ពុជា.
- UN WOMEN. (2020). Prevention of harassment, sexual harassment, discrimination and abuse of authority policy. https://www.unwomen.org/sites/default/files/Headquarters/Attachments/Sections/About%20Us/Accountability/
- UN-Women-Harassment-sexual-harassment-discrimination-and w-abuse-of-authority-policy-en.pdf.

រៀបចំ និងផលិតដោយ

www.sacd.unitedsisterhood.org

info@sacdweb.org

ផ្ទះលេខ១៦៨អេហ្សិត ផ្លូវ២៧បេតេ
សង្កាត់បឹងទំពុន ខណ្ឌមានជ័យ
រាជធានីភ្នំពេញ